# បដិមាព្រះវិស្វកម៌

នៅក្នុងជំនឿព្រហ្មញ្ញសាសនា ព្រះវិស្វកម៌ ឬហៅតាមខ្មែរថា "ព្រះពិស្ណុការ" គឺជាទេពតំណាងឱ្យការបង្កើតថ្មី និងជំនាញបច្ចេកទេស។ គេស្គាល់ព្រះអង្គថាជា "ស្ថាបត្យករនៃចក្រវាល" ឬ "ទេវបុត្រវិស្វករ" ដែលមានតួនាទីសំខាន់ក្នុងការកសាងលោក និងជាអ្នកឧបត្ថម្ភសព្វបែបយ៉ាងដល់សិល្បករ និងជាងទាំងឡាយ។ គេមិនដឹងច្បាស់ថា ខ្មែរចាប់ផ្តើមគោរពព្រះអាទិទេពអង្គនេះចាប់តាំងពីពេលណាមកទេ។ ប៉ុន្តែ មកដល់សម័យអង្គរ ភស្តុតាងដែលគេអាចដឹងអំពីការគោរពទេពនេះ គឺតាមរយៈសិលាចារឹក (បាសែត K.205, ព្រះខ័ន K.908 B) និងបដិមាមួយចំនួន ដែលយើងនឹងលើកយកមកសិក្សានៅក្នុងអត្ថបទខ្លីនេះ។ តើបដិមាព្រះវិស្វកម៌នៅក្នុងសិល្បៈខ្មែរមានលក្ខណៈដូចម្តេចខ្លះ?

នៅក្នុងគម្ពីរហិណ្ឌូមួយចំនួន គេចាត់ទុកព្រះវិស្វកម៌ជាទេវស្ថាបត្យករ ដែលមានសមត្ថភាពអស្ចារ្យលើសសត្វលោក និងទេពទាំងឡាយនៅក្នុងផ្នែកសិល្បៈ និងវិស្វកម្ម។ តួយ៉ាងនៅក្នុងគម្ពីរវិស្ណុបុរាណ ព្រះអង្គ គឺជាអ្នកបង្កើតអាវុធទិព្វសម្រាប់ទេពផ្សេងៗ ដូចត្រង់ឈុតមួយដែលបានរៀបរាប់ថា៖ "នៅពេល **នាងសញ្ញា** ដែលជាបុត្រីរបស់ព្រះវិស្វកម៌ និងជាមហេសីរបស់ព្រះសូរ្យ (ព្រះអាទិត្យ) មិនអាចទ្រាំទ្រនឹងកំដៅដ៏ខ្លាំងក្លារបស់ស្វាមីរបស់ខ្លួនបាន ព្រះវិស្វកម៌ក៏បានយកព្រះសូរ្យមកដាក់លើរង្វង់យន្ត ហើយឈូសរំលាយរស្មីចំនួន១ភាគ៨ចេញ។ រីឯកម្ទេចនៃរស្មីដែលធ្លាក់មកលើដី ត្រូវព្រះអង្គយកទៅស្វឱ្យក្លាយទៅជាអាវុធដ៏មានមហិទ្ធិឫទ្ធិសម្រាប់ទេពនានា ដូចជា ចក្រ (សម្រាប់ព្រះវិស្ណុ) ត្រីសូល៍ (សម្រាប់ព្រះសិវ) និង វជ្រ (សម្រាប់ព្រះឥន្ទ្រ)"។ ចំណែកគម្ពីរភគវតបុរាណ (ស្កន្ទទី១០ ជំពូកទី៥០) រៀបរាប់ថា "នៅពេលដែលព្រះក្រឹស្ណនាំពូជពង្សយាទវគេចចេញពីការឃាយីរបស់ជរាសន្ធ ព្រះវិស្វកម៌បានប្រើឫទ្ធិអំណាចរបស់ទ្រង់កសាងក្រុងទ្វារកាក្នុងរយៈពេលត្រឹមតែមួយយប់ ដែលមានជញ្ជាំងមាស និងប្រាសាទដ៏ស្កឹមស្កៃ"។ លើសពីនេះទៀត តាមរយៈគម្ពីររាមយណបានរៀបរាប់ថា ព្រះវិស្វកម៌ គឺជាអ្នកកសាងក្រុងលង្កានៅលើកំពូលភ្នំត្រីកុតសម្រាប់ព្រះកុវេរ ប៉ុន្តែក្រោយមកក្រុងរាពណ៍បានវាយដណ្តើមយកទីក្រុងនេះពីព្រះកុវេរមកធ្វើជានគររបស់ខ្លួន។ នៅមានក្រុងពិសិដ្ឋជាច្រើនទៀតដែលព្រះវិស្វកម៌បានកសាង ដូចជា ក្រុងឥន្ទ្រប្រស្ថ (យោងតាមគម្ពីរមហាភារត) ក្រុងអមរាវតី (យោងតាមគម្ពីរព្រហ្មបុរាណ និងស្កន្ទបុរាណ)។

អត្ថបទដោយ៖ ម៉ង់ រ៉ាលី

នៅក្នុងបរិបទសង្គមខ្មែរ ព្រះវិស្វកម៌ ដែលគេច្រើនហៅថា "ព្រះពិស្ណុការ" ត្រូវបានគេចាត់ទុកថាជាតួអង្គមេជាងដ៏ស័ក្តិសិទ្ធិ ដូចដែលមានរៀបរាប់នៅក្នុងរឿងព្រេងដែលនិយាយអំពីការកសាងប្រាសាទអង្គរវត្ត ពោល គឺរឿង "ព្រះកេតុមាលា"។ រឿងនោះតំណាលថា "ព្រះឥន្រ្ទបានបញ្ជាឱ្យព្រះវិស្វកម៌ (ព្រះពិស្ណុការ) ចុះមកកសាងប្រាសាទអង្គរវត្ត ដើម្បីឱ្យព្រះកេតុមាលាគង់នៅ។ ព្រះពិស្ណុការបានរៀនសូត្រវិជ្ជាជាងពីស្ថានសួគ៌ ហើយមកមកអនុវត្តដោយការពោយលម្អងថ្មពិសិដ្ឋឱ្យក្លាយជាប្រាសាទអង្គរវត្តភ្លាមៗ។ រហូតមកទល់បច្ចុប្បន្ននេះ ជាងចម្លាក់ ឬជាងសំណង់ក្តី តែងតែរៀបចំពិធី "សែនព្រះពិស្ណុការ" ដើម្បីសុំសេចក្តីសុខ និងសុំឱ្យស្នាដៃរបស់ពួកគេមានភាពប្រណីត និងរឹងមាំបានល្អ។

ជាទូទៅ តាមរយៈគម្ពីរនានារៀបរាប់ថា ព្រះវិស្វកម៌គង់នៅលើសត្វហង្ស ឬសត្វដំរី ដោយមានព្រះសិរ ៤ (តំណាងឱ្យទិសទាំងបួន ឬវេទទាំងបួន) ព្រះបាទ ២ និងព្រះហស្ត ៤ ប្រដាប់ទៅដោយកេតនភណ្ឌសំខាន់ៗដូចជា គម្ពីរ (តំណាងឱ្យចំណេះដឹង និងច្បាប់លោក) ខ្សែរង្វាស់ ឬបន្ទាត់ (តំណាងឱ្យភាពត្រឹមត្រូវក្នុងស្ថាបត្យកម្ម) ក្អមទឹក (តំណាងឱ្យថាមពលនៃការបង្កើតថ្មី និងភាពបរិសុទ្ធ) និងឧបករណ៍សំណង់ផ្សេងៗ ដូចជា ញញួរ ពូថៅ ដែលតំណាងឱ្យការងារសិល្បៈ និងការផលិតអាវុធសម្រាប់ទេព។ លក្ខណៈដែលរៀបរាប់នេះ គេច្រើនឃើញមាននៅក្នុងសិល្បៈឥណ្ឌា។ ប៉ុន្តែ នៅក្នុងសិល្បៈខ្មែរ បដិមាវិស្វកម៌សម័យអង្គរ (ស.វ.ទី១២-១៣) ដែលគេរកឃើញ គឺច្រើននិយមធ្លាក់ឱ្យមានព្រះសិរ ១ និងព្រះហស្ត ២។ ជាក់ស្តែង បដិមាព្រះវិស្វកម៌មួយអង្គ រកឃើញនៅស្រុកគងពិសី ខេត្តកំពង់ស្ពឺ ដែលកំពុងដាក់តាំងបង្ហាញនៅសារមន្ទីរជាតិកម្ពុជា មានលេខបញ្ជី គ.5478 គេកសាងឡើងជាបដិមាទោល ធ្វើអំពីសំរិទ្ធិលាបម្រ័ក្សណ៍ ក្នុងទិដ្ឋភាពកំពុងឈរនៅក្នុងជំហរត្រង់ មានព្រះសិរមួយ និងព្រះហស្តពីរ។ ព្រះហស្តខាងស្តាំមិនមានកាន់កេតនភណ្ឌអ្វីមួយឡើយ តែសំដែងឡើងក្នុងកាយវិការវ្យាឃ្យានមុទ្រា (កាយវិការនៃការបកស្រាយ ឬជម្រាបឱ្យដឹង) ដែលអាចក្នុងន័យបង្ហាញថា ព្រះអង្គកំពុងប្រទាននូវចំណេះដឹងផ្នែកវិទ្យាសាស្ត្រនិងសិល្បៈពាក់ព័ន្ធជាមួយការសាងសង់ និងគណនាប្លង់ដ៏ពិសិដ្ឋ។ រីឯព្រះហស្តខាងឆ្វេង ប្រហែលកាន់ដំបងវែង ឬខ្នាតរង្វាស់ ដែលមានលក្ខណៈជាថ្នាំងៗ ដូចដើមអំពៅ ឬដើមឫស្សី តំណាងឱ្យបច្ចេកទេសសម្រាប់វែងវែងឱ្យត្រូវតាមក្បួនខ្នាតនៃការសាងសង់។ បដិមានេះ គេសិតឡើងដោយមានបំពាក់គ្រឿងអលង្ការជាច្រើនតាំងពីព្រះសិររហូតដល់ព្រះបាទ ជាពិសេស គឺនៅ

ត្រង់ថ្វាសមានរំលេចឱ្យឃើញអំពីតិលកដែលមានរាងមូល បញ្ជាក់ឱ្យឃើញអំពីឋានៈរបស់ទ្រង់ជាទេព និងជាជានិម្មិតរូបតំណាងឱ្យបញ្ញាស្មារតី ការយល់ដឹង និងភាពបរិសុទ្ធ (រូបលេខ១-៣)។ ស្រដៀងគ្នានេះ មានបដិមាមួយអង្គទៀតកំពុងរក្សាទុកនៅសារមន្ទីរជាតិកម្ពុជាដូចគ្នា (លេខបញ្ជី គ.3452) មកពីស្រុកគិរីវង្ស ខេត្តតាកែវ (រចនាបថអង្គរវត្ត ស.វ.ទី១២) ដែលអ្នកជំនាញការសារមន្ទីរសង្ស័យថាជាវិស្វកម្មដែរ មានលក្ខណៈប្រហាក់ប្រហែលគ្នា តែខុសត្រង់ថាព្រះហស្តស្តាំកាន់ដំបងវែង ឬខ្នាតរង្វាស់ និងព្រះហស្តឆ្វេងកាន់ថូទឹក ឬបើមិនដូច្នេះក៏អាចជាឧបករណ៍សំណង់អ្វីមួយផងក៏មិនដឹង (រូបលេខ៤-៥)។

បដិមាព្រះវិស្វកម្មមួយអង្គទៀត ដែលធ្លាប់រត់ពន្ធដោយខុសច្បាប់ពីទីតាំងណាមួយនៃប្រទេសកម្ពុជា និងទើបតែប្រគល់មកពីសហរដ្ឋអាមេរិកកាលពីឆ្នាំ២០២៤ ហើយកំពុងរក្សាទុកនៅសារមន្ទីរជាតិកម្ពុជា។ បដិមានេះសាងអំពីសំលោហៈលាបទឹកមាស និងមានអាយុកាលស្ថិតនៅរចនាបាយ័ន្ត ចុងស.វ.ទី១២ ឬដើមស.វ.ទី១៣ (រូបលេខ៦-៨)។ បដិមាព្រះវិស្វកម្មអង្គនេះ សិតឡើងដោយមានព្រះសិរមួយនិងព្រះហស្តពីរ អង្គុយក្នុងឥរិយាបថបែបវីរាសន (Vīrāsana) ពោលគឺសំដៅដល់ឥរិយាបថអង្គុយដោយលុតជង្គង់ឆ្វេងចុះទៅដី រីឯជង្គង់ស្តាំបញ្ឈរឡើងលើ ដែលទំនងបង្ហាញអំពីភាពមាំមួន និងតួនាទីរបស់ព្រះវិស្វកម្ម ជា "មេជាង" ដែលកំពុងបំពេញការងារយ៉ាងសកម្មនៅក្នុងការងារកសាង។ ព្រះហស្តឆ្វេង ដាក់ផ្ទឹបទៅលើភ្លៅនៅក្នុងឥរិយាបថត្រៀមលក្ខណៈ ឬទប់លំនឹងព្រះកាយ។ រីឯព្រះហស្តស្តាំកាន់វត្ថុអ្វីមួយដែលទំនងជា "ពន្លាក" (គ្រឿងដែកមានមុខមុតសម្រាប់ដាប់) ដែលតំណាងឱ្យតួនាទីព្រះអង្គជាព្រះនៃស្ថាបត្យករ។ បដិមាព្រះវិស្វកម្មសាងអំពីលោហៈនិងអង្គុយក្នុងទម្រង់របៀបនេះ គេធ្លាប់ឃើញមានមួយអង្គទៀតនៅសារមន្ទីរសិល្បៈមេត្រូប៉ូលីតាន់ សហរដ្ឋអាមេរិក ប៉ុន្តែ ខុសត្រង់ថាព្រះហស្តស្តាំរបស់ទ្រង់កាន់ញញួរដាក់នៅលើស្មា។

ជារួមមក យើងអាចទាញសេចក្តីសន្និដ្ឋានថា ការគោរពប្រណិប័តន៍ចំពោះព្រះវិស្វកម្មនៅក្នុងសង្គមខ្មែរនាសម័យបុរាណ គឺមានជំនឿយ៉ាងមុតមាំដូចអាទិទេពផ្សេងៗទៀតនៅក្នុងព្រហ្មញ្ញសាសនាដែរ។ បើទោះបីមិនមានភស្តុតាងណាមួយនៅសម័យមុនអង្គរ (ស.វ.ទី៦-៨) អំពីការប្រណិប័តន៍ព្រះវិស្វកម្មយ៉ាងណាក្តី ភស្តុតាងប្រវត្តិសិល្បៈ និងសិលាចារឹកដែលមាននៅសម័យអង្គរ ជាពិសេស ស.វ.ទី១២ និងទី១៣ បង្ហាញឱ្យឃើញថា ទ្រង់ គឺជាទេពដ៏សំខាន់មួយដែល

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

មនុស្សខ្មែរគោរពជាប់ជាប្រចាំ ព្រោះទ្រង់ជាព្រះនៃការសាងសង់ ឬទេពនៃស្ថាបត្យករ។ ហេតុដូច្នេះហើយ ទើបបានជាបច្ចុប្បន្ននេះ ទ្រង់នៅតែជាទេពដែលគេមិនបំភ្លេចបានឡើយក្នុងពេលកសាងសង់សំណង់អ្វីមួយ។

## បញ្ជីឯកសារពិគ្រោះ


ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ. (១៩៦៣). ប្រជុំរឿងព្រេងខ្មែរ ភាគទី៥. ភ្នំពេញ៖ វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ។

Buitenen, J. A. B. van. (1973). The Mahabharata, Book 1: The Book of the Beginning. University of Chicago Press.

Coedès, George. (1966). *Inscriptions du Cambodge*. Vol. VIII. Hanoi/Paris: EFEO.

Commaille, Jean. (1913). "Notes sur la décoration numismatique des monuments d'Angkor." *Bulletin de l'École française d'Extrême-Orient (BEFEO)*, Vol. 13, No. 1, pp. 1-38.

Dowson, John. (1879). A Classical Dictionary of Hindu Mythology and Religion, Geography, History, and Literature. London: Trübner & Co.

Griffith, R. T. H. (1896). The Hymns of the Rigveda. Benares: E.J. Lazarus.

Goldman, Robert P. (1984). The Ramayana of Valmiki: An Epic of Ancient India. Princeton University Press.

Mani, Vettam. (1975). Puranic Encyclopaedia. Delhi: Motilal Banarsidass.

O'Flaherty, Wendy Doniger. (1975). Hindu Myths: A Sourcebook Translated from the Sanskrit. Penguin Classics.

Tagare, G. V. (1950). The Bhagavata Purana. Ancient Indian Tradition and Mythology Series. Delhi: Motilal Banarsidass.







រូបលេខ១-៣៖ បដិមាព្រះវិស្វកម្មមកពីស្រុកគងពិសី ខេត្តកំពង់ស្ពឺ (ស.វ.ទី១២) (សារមន្ទីរជាតិកម្ពុជា)





រូបលេខ៤-៥៖ បដិមាព្រះវិស្វកម្មមកពីស្រុកគិរីវង្ស ខេត្តតាកែវ (ស.វ.ទី១២) (សារមន្ទីរជាតិកម្ពុជា)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី





រូបលេខ៦-៨៖ បដិមាព្រះវិស្វកម៌មិនស្គាល់ប្រភព (ស.វ.ទី១២-១៣) (សារមន្ទីរជាតិកម្ពុជា)

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយ៖ ម៉ង់ រ៉ាលី